ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៣៦ ត្រីមាសទី០២ ឆ្នាំ២០២១

រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

២២-៧-២០២១ -ព្រះរាជក្រម នស/រកម/០៧២១/០០៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណេសិន-ណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងតាតៃលើ អនុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង ៤៣៥៥

២~ព្រះរាជក្រឹត្យ

៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៤ ស្តីពី ការតែងតាំងមុខតំណែង លោកជំទាវ **រត្ន ម៉ានី** ជាអនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៤៣៧៧

៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ឆុខ សេដ្ឋា** ជាទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ អគ្គនាយក ៤៣៧៨

៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៦ ស្តីពី ការផ្តល់សញ្ញាតិខ្មែរ ដោយសញ្ញាតូបនីយកម្ម ដល់លោក **ប៊ួយ ឌឹកធ្វៀន** **(BUI DUC TUYEN)** ជនជាតិវៀតណាម សញ្ញាតិវៀតណាម ដោយប្តូរឈ្មោះជា **ប្រោន ខេវិន** **(BROWN KEVIN)** ៤៣៧៩

៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៧ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ស៊ិន ដារ៉ា** ពីនាយកខុទ្ទកាល័យឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងតែងតាំង និងផ្តល់ឋានៈ ឯកឧត្តម ៤ រូប ៤៣៨០

១០-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម ២រូប ជាទីប្រឹក្សា និងជាជំនួយការ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ ៤៣៨២

១៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥១៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តមសាស្ត្រាចារ្យ **សេង គីរេក្ស** ជាទីប្រឹក្សាក្រសួងសុខាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ ៤៣៨៣

១៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៣រូប ៤៣៨៤

១៣-៧-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២១ ស្តីពី និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ នៅក្រសួងចំនួន ៣ ដល់មន្ត្រីរាជការ ១២រូប និងនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ នៅក្រសួងចំនួន ៤ ដល់មន្ត្រីរាជការ ១៨ រូប ៤៣៨៥

១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២២ ស្តីពី ការដាក់មន្ត្រីរាជការ ៧៤ រូប របស់ក្រសួងស្ថាប័នចំនួន ២២ ឱ្យចូលនិវត្តន៍	៤៣៨៨
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **យីវ ខាយម៉ាន់អេនឌ្រូ** **(YIU KAI MAN ANDREW)** ជនជាតិចិន សញ្ជាតិចិន	៤៣៩៤
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី វ៉ៃ** **(LI WEI)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **តាំង ឃាង** **(TAING KHEANG)**	៤៣៩៥
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **យ៉ាប លៀនយុក** **(YAP LIAN YOKE)** ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី ដោយប្តូរឈ្មោះជា **យ៉ាប ដូដូ** **(YAP DODO)**	៤៣៩៦
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **ហ័ង លីនយីង** **(HUANG, LINYING)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ផៃ ឈី** **(PEI QI)**	៤៣៩៧
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លូ ជា** **(LU, JIE)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ចឹង រ៉ាន** **(ZHENG RAN)**	៤៣៩៨
១៣-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សៀវ ចឹងយាន** **(XIAO, ZHENGYUAN)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ឆិន ចុងស៊ី** **(CHEN ZONG XI)**	៤៣៩៩
១៥-៧-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៧២១/៥២៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី លួក អែ** **(LEE LAUK AE)** ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា	៤៤០០

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៩-៦-២០២១	-អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២០០៣ (ពីរពាន់បី) ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល	៤៤០១
២៩-៦-២០២១	-អនុក្រឹត្យលេខ ១០១ អនក្រ.បក ស្តីពី ការធ្វើអនុប្បយោគ	៤៤០៤
២៩-៦-២០២១	-អនុក្រឹត្យលេខ ១០២ អនក្រ.បក ស្តីពី ការគ្រប់គ្រង និងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល	៤៤០៧

២៩-៦-២០២១ -អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ៤៤១១

១៦-៦-២០២១ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៤២២

១៦-៦-២០២១ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៤២៣

១៦-៦-២០២១ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៤២៤

២១-៦-២០២១ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ៤៤២៦

២២-៦-២០២១ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៤២៧

២២-៦-២០២១ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៤២៩

២២-៦-២០២១ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៤៣១

២~សេចក្តីសម្រេច

២៤-៦-២០២១ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះកម្ពុជាសម្រាប់ជំរុញការអនុវត្តអនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃ ស្តីពីតំបន់ទាមទារដែនសមុទ្រត្រួតគ្នានៃតំបន់ខ្ពង់រាបបាតសមុទ្រឆ្នាំ២០០១ ៤៤៣២

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៨-១១-២០២០ -ប្រកាសលេខ ៥៧២ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេលីត វីន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ៤៤៣៦

១៨-១១-២០២០ -ប្រកាសលេខ ៥៧៣ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហោន ស៊ើវេន អឹភែរឹល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤៤៣៩

១៨-១១-២០២០ -ប្រកាសលេខ ៥៧៤ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បាវហ្សាន់ អ៊ិនដាស-ស្ទ្រៀល បង្កើតរោងចក្រ ផលិតស្បែកជើង គ្រឿងបន្សំស្បែកជើង កំរាលជ័រ និងទ្រនាប់ម៉ៅ ៤៤៤២

១៨-១១-២០២០ -ប្រកាសលេខ ៥៧៥ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាត បេស (ខេមបូឌា) អេឡិកទ្រីខល & ហូម អឹផ្លាយអិន ឯ.ក បង្កើតរោងចក្រ ផ្គុំតម្លើងគ្រឿងបរិក្ខារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកគ្រប់ប្រភេទ ៤៤៤៥

១៨-១១-២០២០ -ប្រកាសលេខ ៥៧៦ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធេនថេក ខមភើហ្សាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្លាស់ទោចក្រយាន (កង់) ៤៤៤៨

១៨-១១-២០២០ -ប្រកាសលេខ ៥៧៧ ឧវបន.កឧ.ប្រក ១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចូវ អ៊ី ស៊ូ មេនូហ្វេក-ឆឺរីង ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៤៤៥១

២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

១២-៣-២០២០	-ប្រកាសលេខ ០០៧៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៧៥ រថ.អប្រក.លអ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០	៤៤៥៤
១៨-៣-២០២០	-ប្រកាសលេខ ០០៧៦ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៧៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០	៤៤៥៨
១៨-៣-២០២០	-ប្រកាសលេខ ០០៧៧ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០០៧៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០	៤៤៦២
១៨-៣-២០២០	-ប្រកាសលេខ ០០៧៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៧៨ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០	៤៤៦៦
១៨-៣-២០២០	-ប្រកាសលេខ ០០៧៩ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០០៧៩ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០	៤៤៧០

៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៦-៨-២០២០	-ប្រកាសលេខ ៣៣៧៣ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម	៤៤៧៤
៦-៨-២០២០	-ប្រកាសលេខ ៣៣៧៦ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម	៤៤៧៥
១០-៨-២០២០	-ប្រកាសលេខ ៣៣៩៣ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម	៤៤៧៦

៤~ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៤-៩-២០២១	-ប្រកាសលេខ ១៥០ កយ.ប្រក/២០ ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្ស	៤៤៧៧

ព្រះរាជក្រម

នស/រកម/០៧២១/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ឧបករណ៍សិន សម្រាប់គម្រោងអគិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណោសិនណាល ហៅវី ម៉ាស៊ីនណឺរី ឧបតើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

មាត្រា១ .-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុន ឆាយណា ណោសិនណាល ហៅវី ម៉ាស៊ីនណឺរី ឧបតើរេសិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ឆាយណា ណោសិនណាល ហៅវី ម៉ាស៊ីនណឺរី ឧបតើរេសិន និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ឆាយណា ណោសិនណាល ហៅវី ម៉ាស៊ីនណឺរី ឧបតើរេសិន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២០។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២១

នស/រកម.០៧២១.០៤១

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

សេចក្តីព្រាង

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណោសិនណាល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

មាត្រា១ .-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុន ឆាយណា ណោសិនណាល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុន ឆាយណា ណោសិនណាល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ឆាយណា ណោសិនណាល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២០។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០២១
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៦។

ថ្ងៃ ខែ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ០៤ សជណ.កបច

សេចក្តីថ្លែងហេតុ

អំពី

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានានូវទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណេសិនណាល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

សន្តិភាព ស្ថិរភាពនយោបាយ ឯកភាពជាតិ គួបផ្សំនឹងស្ថានភាពកាន់តែល្អប្រសើរនៅក្រោយការបោះឆ្នោតសាកលឆ្នាំ២០១៨ បានធ្វើឱ្យសកម្មភាពវិនិយោគកើនលើសពេលមុនៗ និងបានជះឥទ្ធិពលដល់តម្រូវការប្រើប្រាស់អគ្គិសនីនៅឆ្នាំ២០១៩ កើនឡើងយ៉ាងគំហុកលើសការគ្រោងទុក។ ដើម្បីបំពេញឱ្យបានតាមតម្រូវការប្រើប្រាស់អគ្គិសនីផងនិងក្នុងស្មារតីប្រុងប្រយ័ត្នខ្ពស់ ដែលអាចធានាបានថាការអភិវឌ្ឍវិស័យថាមពលស្ថិតក្នុងកម្រិតសមស្រប រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនទីប្រឹក្សាមកពីប្រទេសជប៉ុនសហការជាមួយគណៈកម្មការអន្តរក្រសួងដែលដឹកនាំដោយក្រសួងរ៉ែនិងថាមពល ធ្វើការសិក្សានិងរៀបចំផែនការមេអភិវឌ្ឍវិស័យថាមពលសម្រាប់ឆ្នាំ២០២០ ដល់ឆ្នាំ២០៣០ និងសម្រាប់រយៈពេលវែងពីឆ្នាំ២០២០ ដល់ឆ្នាំ២០៤០។ តាមការវិភាគនិងព្យាករណ៍របស់អ្នកជំនាញ ប្រសិនបើពុំមានអ្វីប្រែប្រួលទេ កំណើននៃសេចក្តីត្រូវការអគ្គិសនីនឹងបន្តកើនឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខ មុននឹងថយចុះបន្តិចវិញមកក្បែរអត្រាកំណើនប្រហាក់ប្រហែលប្រទេសជិតខាង។ ស្ថិតក្នុងស្ថានភាពនេះ និងដើម្បីធានាសុវត្ថិភាពនិងសន្តិសុខនៃការផ្គត់ផ្គង់អគ្គិសនីនៅឆ្នាំបន្តបន្ទាប់ទៀត រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការអភិវឌ្ឍប្រភពអគ្គិសនីបន្ថែមពីឆ្នាំ២០២០ ដល់ ឆ្នាំ២០៣០ ស្របទៅតាមការព្យាករណ៍សេចក្តីត្រូវការអគ្គិសនីថ្មីនេះ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនីនិងអនុស្ថានីយក៏ត្រូវអភិវឌ្ឍឱ្យបានស្របទៅនឹងការអភិវឌ្ឍប្រភពថាមពលផងដែរ។

ផ្អែកលើលទ្ធផលនៃការសិក្សាខាងលើ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ បានសម្រេចឯកភាពទាំងស្រុងលើគម្រោងវិនិយោគចំនួន៣ រួមមាន៖ ទី១-គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ នៅស្រុកថ្មបាំង ខេត្តកោះកុង។ ទី២-គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ។ និងទី៣-គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីក្រុងបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ។

ក្រុមហ៊ុន ឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន ទទួលបានសម្បទានអនុវត្តគម្រោង អភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ នៅខេត្តកោះកុង តាមលក្ខខណ្ឌគន្លឹះសំខាន់ៗ ដូចខាងក្រោម៖

១- ទីតាំងគម្រោង៖ គម្រោងវារីអគ្គិសនីស្ទឹងតាតៃលើ ស្ថិតនៅចំណុចប្រសព្វនៃដៃស្ទឹងចំនួន២ គឺស្ទឹងតាតៃនិងស្ទឹងកែប ក្នុងភូមិសាស្ត្រឃុំប្ញស្សីជ្រុំ និងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង ចម្ងាយ ៤៦គីឡូម៉ែត្រ ខាងជើងឆៀងខាងកើតនៃទីរួមខេត្តកោះកុង។

២- រូបភាពវិនិយោគគឺសាងសង់ អាជីវកម្ម ផ្ទេរ (BOT)។

៣- រយៈពេលសម្បទានសរុប៣៩ឆ្នាំ ក្នុងនោះ សាងសង់៤ឆ្នាំ និងធ្វើអាជីវកម្ម៣៥ឆ្នាំ។

៤- ការងារដែលក្រុមហ៊ុនត្រូវធ្វើ រួមមាន៖ ទំនប់ទឹក អាងស្តុកទឹក បំពង់បង្ហូរទឹក ស្ពាន ថ្នល់ ស្ថានីយវារីអគ្គិសនី អានុភាពដំឡើង១៥០មេហ្គាវ៉ាត់ អនុស្ថានីយមានរបាររទេះ ខ្សែបញ្ជូនសម្រាប់ភ្ជាប់ជាមួយបណ្ដាញជាតិចំនួន៩ និងហេដ្ឋារចនាសម្ព័ន្ធរួមផ្សំដទៃទៀត។

៥- ទំហំទុនវិនិយោគសរុប៖ ៣៨៩ ៤១៤ ០០៤ ដុល្លារអាមេរិកក្នុងនោះមានទុនផ្ទាល់ ៣០% និងកម្ចីធនាគារ ៧០% តាមអត្រាការប្រាក់ ៥,៧០%។

៦- បរិមាណថាមពលផលិតប្រចាំឆ្នាំ ៥២៧លានគីឡូវ៉ាត់ម៉ោង ដែលក្នុងនោះ៖
   - រដូវវស្សា (រយៈពេល៥ខែ ចាប់ពីថ្ងៃទី១ ខែមិថុនា រហូតដល់ ថ្ងៃទី៣១ ខែតុលា) ៣៧៣លានគីឡូវ៉ាត់ម៉ោង
   - រដូវប្រាំង (រយៈពេល៧ខែ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា រហូតដល់ ថ្ងៃទី៣១ ខែឧសភា) ១៥៤លានគីឡូវ៉ាត់ម៉ោង។

៧- ថ្លៃលក់អគ្គិសនី៖ ៧,៩២សេនអាម៉េរិក/គីឡូវ៉ាត់ម៉ោង។

៨- ផលតាមអត្រាផ្ទៃក្នុង៖ ៧,៦២%។

៩- អំពីការលើកទឹកចិត្តវិនិយោគ (ដូចគម្រោងមុនៗដែរ)៖
   - លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល៩ឆ្នាំ គិតចាប់ពីឆ្នាំប្រតិបត្តិការអាជីវកម្មដំបូង។
   - លើកលែងពន្ធគយ អាករលើតម្លៃបន្ថែម និងអាករពិសេស ជាបន្ទុករបស់រដ្ឋលើការនាំចូលម៉ាស៊ីន ឧបករណ៍ សម្ភារៈ បរិក្ខារ និងគ្រឿងបន្លាស់ សម្រាប់ការសាងសង់គម្រោងក្នុងរយៈពេលសាងសង់ និងឆ្នាំទី១នៃឆ្នាំប្រតិបត្តិការ។
   - លើកលែងថ្លៃសួយសារលើធនធានរ៉ែសំណង់ (គ្រួស ខ្សាច់ ថ្ម អាចម៍ដី ដីក្រហម) ដែលប្រើប្រាស់ក្នុងការសាងសង់គម្រោង។
   - កាតព្វកិច្ចក្រៅពីនេះ ត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនានា ជាធរមាន។

១០- អំពីចំណូលនិងអត្ថប្រយោជន៍ផ្សេងៗ៖

ផ្អែកតាមច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពន្ធដារជាធរមាន និងការលើកទឹកចិត្តវិនិយោគ រដ្ឋនឹងទទួលបានចំណូលពន្ធពីគម្រោងនេះ ដូចខាងក្រោម៖

(១)- ពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុកលើចំណាយការប្រាក់ និងពន្ធកាត់ទុកលើការបែងចែកភាគលាភ សរុបចំនួន ១៩៩ ៧០៥ ៩៨៤ដុល្លារអាមេរិក ក្នុងរយៈពេលសម្បទាន៣៩ឆ្នាំ ឬជាមធ្យម ៥ ១២០ ៦៦៦ដុល្លារអាមេរិកក្នុង១ឆ្នាំ។

(២)- ក្នុងករណីអាករលើតម្លៃបន្ថែមត្រូវបានដាក់ឱ្យអនុវត្ត រដ្ឋនឹងទទួលបានចំណូលពីអាករនេះសរុបចំនួន ១៤៤ ៦២៣ ៥៥៦ដុល្លារអាមេរិក ក្នុងរយៈពេល៣៥ឆ្នាំ នៃអាណត្តិប្រតិបត្តិការអាជីវកម្មឬជាមធ្យម ៤ ១៣២ ១០០ដុល្លារអាមេរិកក្នុង១ឆ្នាំនៃឆ្នាំប្រតិបត្តិការអាជីវកម្ម។

(៣)- ចំណូលក្រសួង ស្ថាប័នរដ្ឋដទៃទៀត រួមមាន៖

- មូលនិធិបរិស្ថាន(ក្រសួងបរិស្ថាន) សរុបចំនួន ៧០០ ០០០ដុល្លារអាមេរិកឬជាមធ្យម ២០ ០០០ ដុល្លារអាមេរិកក្នុង១ឆ្នាំនៃឆ្នាំប្រតិបត្តិការ។
- មូលនិធិកសាងសមត្ថភាពធនធានមនុស្ស(អគ្គិសនីកម្ពុជា) សរុបចំនួន ៧ ០០០ ០០០ដុល្លារអាមេរិក ឬជាមធ្យម ២០០ ០០០ដុល្លារអាមេរិក ក្នុង១ឆ្នាំនៃឆ្នាំប្រតិបត្តិការ។
- កម្រៃអាជ្ញាបណ្ណ(អាជ្ញាធរអគ្គិសនីកម្ពុជា) សរុបចំនួន ៦ ៧៥៦ ៤០០ដុល្លារអាមេរិក ឬជាមធ្យម ១៩៣ ០៤០ដុល្លារអាមេរិក ក្នុង១ឆ្នាំនៃឆ្នាំប្រតិបត្តិការ។ ក្រុមហ៊ុនត្រូវបង់កម្រៃអាជ្ញាបណ្ណតាមចំនួនទឹកប្រាក់ថេរ។ អគ្គិសនីកម្ពុជា ត្រូវកាត់ទុកជាមុននិងបង់ជូនអាជ្ញាធរអគ្គិសនីកម្ពុជាជំនួសក្រុមហ៊ុន។ ជាគោលការណ៍ កម្រៃអាជ្ញាបណ្ណនឹងត្រូវកាត់បន្ថយជាលំដាប់។ ទៅថ្ងៃអនាគត នៅពេលដែលកម្រៃអាជ្ញាបណ្ណថយចុះ ប្រាក់លំអៀងនេះនឹងបានជាប្រយោជន៍របស់អគ្គិសនីកម្ពុជាដែលជាសហគ្រាសរដ្ឋ។

(៤)- ចំណូលពន្ធខាងលើ នៅមិនទាន់គិតបញ្ចូលចំណូលពន្ធមួយចំនួនទៀត ដូចជា ពន្ធលើប្រាក់បៀវត្សរ៍ ពន្ធកាត់ទុកលើការជួលនានា និងពន្ធដោយប្រយោលដទៃទៀត។

(៥)- អត្ថប្រយោជន៍ផ្សេងៗដែលទទួលបានពីគម្រោង៖

- ទទួលបានថាមពលប្រចាំឆ្នាំជាមធ្យម ៥២៧លានគីឡូវ៉ាត់ម៉ោងក្នុងតម្លៃថេររយៈពេល៣៥ឆ្នាំ គឺ ៧,៩២សេនអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង។
- ផ្តល់លទ្ធភាពឱ្យគម្រោងវារីអគ្គិសនីស្ទឹងតាតែក្រោមបច្ចុប្បន្ន ផលិតថាមពលបន្ថែមនៅរដូវប្រាំងចំនួន ១០៨លានគីឡូវ៉ាត់ម៉ោងក្នុង១ឆ្នាំ។
- ការបញ្ចេញទឹកស្ថានីយវារីអគ្គិសនីនៅរដូវប្រាំង ធ្វើឱ្យកំណាត់ដៃស្ទឹងតាតៃនិងស្ទឹងកែប មានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចម្រុះរបស់កំណាត់ដៃនៃស្ទឹងទាំងពីរនេះ។
- គម្រោងនេះ នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជា ផ្លូវចូលទៅគម្រោងដែលមានប្រវែងសរុបប្រមាណ ៤២,៦១គីឡូម៉ែត្រ និងស្ពានឆ្លងកាត់ស្ទឹងតាតៃ។
- ហេដ្ឋារចនាសម្ព័ន្ធនៃគម្រោងនឹងរួមចំណែកធ្វើឱ្យមានការកែប្រែទេសភាពតំបន់នេះ ទៅជាតំបន់ទេសចរណ៍ធម្មជាតិ។
- គម្រោងនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេស ប្រជាពលរដ្ឋមូលដ្ឋាន។

- គម្រោងវារីអគ្គិសនីស្ទឹងតាតៃលើនេះ នឹងរួមចំណែកផ្តល់ស្ថិរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនី កាន់តែធានាបាននូវតម្លៃភ្លើងសមរម្យ និងឯករាជ្យភាពក្នុងការផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជា។

១១- អំពីផលប៉ះពាល់បរិស្ថាននិងសង្គមៈ

(១)- ផលប៉ះពាល់ៈ

- ផ្ទៃដីចំការ ២,២៨ហិកតា
- ផ្ទៃដីបុះ (ដីចំការបោះបង់ចោល) ៩ហិកតា
- ដំណាំឈើហូបផ្លែសរុប ៣ ៩៤៩ដើម/គុម្ព (ក្នុងនោះ ៣ ០០៣ដើម ឱ្យផល និង ៩៤៦ដើម មិនទាន់ឱ្យផល) ដែលជារបស់ប្រជាពលរដ្ឋ ចំនួន ៤គ្រួសារ។
- ប៉ះពាល់គម្របព្រៃឈើសរុបចំនួន ១ ៧០៦,៣៦ហិកតា រួមមានៈ
  - គម្របព្រៃឈើ ១៤២,៣៦ហិកតា
  - គម្របព្រៃស្រោង ១ ៣៣៦,០០ហិកតា
  - គម្របព្រៃល្បាយឫស្សី ២២៨,០០ហិកតា
- ក្នុងតំបន់គម្រោងមានថនិកសត្វ ៤៦ប្រភេទ ពពួកបក្សី ១១២ប្រភេទ ល្មូននិងកង្កែប ឬ ថលជលិក ៤៩ប្រភេទ និងត្រីទឹកសាប ៣៦ប្រភេទ។

(២)- វិធានការដោះស្រាយផលប៉ះពាល់ៈ

- ក្រុមហ៊ុននឹងធ្វើការបញ្ចេញលំហូរទឹកពីអាងទឹកស្ទឹងតាតៃ ចំនួន ១,៤៥ម៉ែត្រគ្រីគុណ/វិនាទី ដើម្បីរក្សាលំនឹងធនធានបរិស្ថានស្ទឹងតាតៃ និង ០,២ម៉ែត្រគ្រីគុណ/វិនាទី សម្រាប់ស្ទឹងកែប
- ក្រុមហ៊ុនគ្រោងមូលនិធិបរិស្ថាននិងសង្គមសម្រាប់រយៈពេល៥ឆ្នាំ សរុបចំនួន ១១៥ ០០០ ដុល្លារអាមេរិក រួមមានៈ សម្រាប់ការដាំដើមឈើឡើងវិញ ៥០ ០០០ដុល្លារអាមេរិក ការចូលរួម អភិរក្សជលផល ១២ ៥០០ដុល្លារអាមេរិក ការចូលរួមគាំពារបរិស្ថាន ១៥ ០០០ដុល្លារអាមេរិក ការបណ្តុះបណ្តាលជំនាញដល់ប្រជាពលរដ្ឋសហគមន៍ ១២ ៥០០ដុល្លារអាមេរិក និងការ ចូលរួមអភិវឌ្ឍភូមិ-ឃុំ ២៥ ០០០ដុល្លារអាមេរិក។
- ក្រុមហ៊ុនគ្រោងថវិកាចំនួន ៤៨០ ៤០០ដុល្លារអាមេរិកសម្រាប់សំណងដល់ប្រជាពលរដ្ឋ ៤គ្រួសារ ដែលប៉ះពាល់ដោយសារគម្រោងនេះ។

ជារួម ឃើញថាផលប៉ះពាល់ពីគម្រោងស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន រីឯផលប្រយោជន៍ទទួលបាន ពីគម្រោងមានទំហំធំផងដែលអាចរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល រួមទាំង គោលនយោបាយកាត់បន្ថយថ្លៃលក់អគ្គិសនីផង ដែលនឹងជំរុញបន្ថែមទៀតនូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ នៅស្រុកថ្មបាំង ខេត្តកោះកុង រួមមានបីមាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភា មេត្តាពិនិត្យនិងអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណោសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង ជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០២១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៦១...សប្រទ

ថ្ងៃចន្ទ ៨ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២០

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសម្បទាន
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេច របស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង កិច្ចព្រមព្រៀងជួលទីតាំង ជាមួយក្រុមហ៊ុន China National Heavy Machinery Corporation (CHMC) និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន China National Heavy Machinery Corporation (CHMC) សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព ១៥០ មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញគ្រប់កិច្ចការ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

N° 61 DFP

Phnom Penh, 23 November, 2020

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0918/925 dated 06 of September 2018 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram NS/RKM/0618/012 dated 28 of June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram 03/NS/94 dated 05 Of August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 Of October 2007 promulgating the Law on Concessions
- Seen the Royal Kram NS/RKM/1219/025 dated 20 of December 2019 promulgating the Law on Finance for Management of the Year 2020
- Seen Sub-decree 111 អនុក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 23 October 2020

THE ROYAL GOVERNMENT

Delegates herewith to H.E. Dr. AUN PORNMONIROTH, Deputy Prime Minister, Minister of Economy and Finance, full power to sign the Implementation Agreement, Lease Agreement, and the Governmental Guarantee of Payments by the EDC/MME to China National Heavy Machinery Corporation (CHMC) for the Development of 150 MW Upper Stung Tatay Hydroelectric Project on BOT Basis in Koh Kong Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២០

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ	÷	**លោក** XIAO PING **ប្រធានក្រុមហ៊ុន** China National Heavy Machinery Corporation
អាសយដ្ឋាន	÷	Bldg.II-8, Hanwei International Plaza, 186 Nansihuanxi Road Fengtai District, Beijing 100070, P.R. China.
ទូរស័ព្ទ	÷	+86 10 6821 1861
ទូរសារ	÷	+86 10 6821 7772

យោង ÷

(ក) សិទ្ធិប្រទាន លេខ ៦១ សប្រទ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (ឧបសម្ព័ន្ធ១)។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល** (ក.រ.ថ) និង **ក្រុមហ៊ុន** China National Heavy Machinery Corporation (**ក្រុមហ៊ុន**)។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (**អ.ក**) ដែលបានចុះកិច្ចព្រមព្រៀងទិញថាមពល (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០។

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពល ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាម PPA និង/ឬ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

IA ក្នុងករណីដែលក្រុមហ៊ុនមិនអាចអនុវត្តគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ។

(ង) តាមការតម្រូវក្នុងប្រការ ៥.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (**អ្នកធានា**) បានយល់ព្រមផ្តល់លិខិតធានាលើកាតព្វកិច្ចទូទាត់ ដោយ អ.ក/ក.រ.ថ ស្របតាម PPA និង IA។

ដូច្នេះ យើងខ្ញុំសូមធានា ថា÷

១. អ្នកធានា សូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុននូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុនស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA (**លិខិតធានា**)។

២. លិខិតធានានេះ ត្រូវជាការធានាជាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ និង/ឬ អ.ក ស្របតាម IA ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ ឬ អ.ក។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៧.១ នៃ PPA ឬសំណើសុំការទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានាត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ហើយពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុនស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬដកសិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រដែលមិនទាន់ទូទាត់ផ្សេងទៀត។ ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំការទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់

អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). ក្រុមហ៊ុន China National Heavy Machinery Corporation (ក្រុមហ៊ុន) បានធ្វើសំណើសុំការទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ ..... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.... ខែ..... ឆ្នាំ...... រវាងអ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក/ក.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក/ក.រ.ថ និងក្រុមហ៊ុនទេ។

(៣). សំណើសុំការទូទាត់ពី ក.រ.ថ/អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ/អ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានាសូមអះអាង និងធានានៅថ្ងៃនេះថា÷

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតតាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ចំពោះអ្នកធានា អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រម ដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។
- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចាប់ផ្ដើមការសាងសង់ (Construction Commencement Date) រហូតដល់បញ្ចប់អាណត្តិ នៃ IA ឬ PPA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុនទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ប្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាព លុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្ដល់ឱ្យក្រុមហ៊ុនដោយលិខិតធានានេះ គឺជាការផ្ដល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្ដល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្ដល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅថ្ងៃប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិតតាមអាសយដ្ឋាន ឬលេខទូរសារ ចែងបញ្ជាក់ខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ	÷	ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អាសយដ្ឋាន	÷	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ	÷	(៨៥៥) ២៣ ៨៩០ ៦៦៦

សម្រាប់ ក្រុមហ៊ុន÷

ជូនចំពោះ	÷	លោកប្រធានក្រុមហ៊ុន ក្រុមហ៊ុន China National Heavy Machinery Corporation
អាសយដ្ឋាន	÷	Bldg.II-8, Hanwei International Plaza

186 Nansihuanxi Road Fengtai District,

Beijing 100070, P.R. China.

ទូរស័ព្ទ ÷ +86 10 6821 1861

ទូរសារ ÷ +86 10 6821 7772

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាពជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ ត្រូវគ្រប់គ្រងដោយ និងបកស្រាយ តាមច្បាប់អង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យផងដែរ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាននៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើ មានភាពមិនស្របគ្នាដោយអន្លើរវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយដែលមានយុត្តាធិការ ធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះ មានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយ

តុលាការមជ្ឈត្តវិនិច្ឆ័យ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្ដីសម្រេច របស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្ដីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង PPA ឬ IA ជាយថាហេតុ។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ។ ជាកម្មវត្ថុនៃការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្ដឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានាចំពោះក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកធានា ចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ។

១៤. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ IA និង PPA ប្រសិនបើគ្មានការទាមទារណាមួយ ហើយនៅរក្សាការធានានេះដដែល ប្រសិនបើមានការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពីក្រុមហ៊ុនជូនមកអ្នកធានា ដែលត្រូវតែទទួលបានដោយអ្នកធានា មុនកាលបរិច្ឆេទនោះ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិបញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អាន ពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

№ 006 MEF/..............

Phnom Penh, 22 December 2020

GOVERNMENT GUARANTEE OF PAYMENTS

To : China National Heavy Machinery Corporation
Address : Bldg.II-8, Hanwei International Plaza,
186 Nansihuanxi Road Fengtai District,
Beijing 100070,P.R. China
Fax No. : +86 10 6821 7772
Tel No. : +86 10 6821 1861
Attention : Mr. Xiao Ping, President

Dear Sir,

We refer to:

(A) Delegation of Full Powers No. 61 DFP dated 23 November 2020, by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia (Attachment 1).

(B) The Implementation Agreement **("IA")** dated 08 December 2020, entered into between the Royal Government of Cambodia **("RGC")** represented by Minister of Ministry of Mines and Energy **("MME")** and China National Heavy Machinery Corporation (the **"Company"**).

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Yukunthor Street, Daun Penh, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees (**"EDC"**) has entered into a Power Purchase Agreement (**"PPA"**) with the Company dated 08 December 2020.

(D) The RGC agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with the PPA and/or

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

the IA in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance ("**MEF**") on behalf of Royal Government of Cambodia (the "**Guarantor**") has agreed to issue this Guarantee of the payment obligations of EDC/MME under the PPA and the IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA (the "**Guarantee**").

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME or EDC. At any time after sixty (60) days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from the Company to EDC or MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s). All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating,

without the obligation to substantiate, that:

"We hereby certify that:

(1) China National Heavy Machinery Corporation (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars [•] [insert amount] in accordance with Section 1 of the Guarantee dated [•], between the Guarantor and the Company;

(2) The amount specified above is due and payable by EDC/MME under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company;

(3) Demand in writing for payment from EDC/MME has been made;

(4) Such amount, on the date hereof, remains unpaid by EDC/MME."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against the Guarantor or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PPA and for so long thereafter as any amount owed to the Company by MME or EDC in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall

constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) when presented personally, or
   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

For the Guarantor	:	
Attention	:	Minister, Ministry of Economy and Finance
Address	:	Ministry of Economy and Finance
Tel.	:	023 890 666
For the Company	:	
Address	:	Bldg.II-8, Hanwei International Plaza, 186 Nansihuanxi Road Fengtai District, Beijing 100070,P.R. China
Fax No.	:	+86 10 6821 7772
Tel No.	:	+86 10 6821 1861
Attention	:	President, China National Heavy Machinery Corporation

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ប្លង់បង្ហាញទីតាំងដី

ស្នើសុំកាត់ចេញពីផ្ទៃដីមន្ទីរពាណិជ្ជកម្មខេត្ត (ស្រុកល្វាឯម ខេត្តកណ្ដាល)

ស្ថិតនៅភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល

ចំណុចទីតាំងឈរជើងម៉ាស៊ីន		
PID	Northing (m)	Easting (m)
BMKD01	1269165.4640	494347.9020

តារាងនិយាមការនៃចំណុចព្រំដី		
Projection UTM, Zone48N, Datum WGS84		
PID	Northing (m)	Easting (m)
1420	1275921.0210	504801.4560
1421	1275941.5960	504740.6210
1422	1275994.3460	504761.0470
1423	1275977.8360	504820.3450





វាស់វែងដោយម៉ាស៊ីន DGPS T300Plus

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

វាស់វែងដោយ:

ប៊ុន វិបុលរិទ្ធ

កំណត់សំគាល់

◎ បង្គោលព្រំដី

— ព្រំដី

▭ ដីរបស់មន្ទីរពាណិជ្ជកម្មខេត្ត

បានត្រួតពិនិត្យត្រឹមត្រូវ

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកល្វាឯម

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

អ៊ុក~ឌឿប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០១ អនុក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុប្បយោគ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទប្បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្វ្រីនគ្រេដ
- លិខិតលេខ ០៦៨ កបាត ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងពាណិជ្ជកម្ម។

សម្រេច

មាត្រា១.-

ត្រូវបានធ្វើអនុប្បយោគផ្ទៃដី២កន្លែង មានទំហំសរុប ៦៦៩ (ប្រាំមួយរយហុកសិបប្រាំបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ២ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដូចមានបង្ហាញក្នុងប្លង់ទីតាំងដី-ឃ្លាំងខេត្តព្រះសីហនុភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២.-

ប្រគល់ផ្ទៃដីទំហំ ៥២៩ (ប្រាំរយម្ភៃប្រាំបួន) ម៉ែត្រការ៉េ ជូនដល់គ្រួសារលោក **តេជ ងួន** និងផ្ទៃដីទំហំ ១៤០ (មួយរយសែសិប) ម៉ែត្រការ៉េ ជូនដល់គ្រួសារលោក **ស៊ឹម សុគ្គា**។

ផ្ទៃដីដែលបានធ្វើអនុប្បយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងពាណិជ្ជកម្ម ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋស្របតាមនីតិវិធីជាធរមាន។

មាត្រា៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
ក្រុមហ៊ុនហ្គ្រីនត្រេដ

ប្លង់បង្ហាញទីតាំងដីស្នើសុំជូនលោកស៊ឹម សុត្ថា



ថ្ងៃសុក្រ ៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១
ជូនហោយ

ម៉ម តារាណាវិទ្ធ

នាយកដ្ឋានបច្ចេកទេស
ប្រធាន

ពេជ្រ_សំអាត

បានឃើញ និងឯកភាព
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
ប្រធានអគ្គនាយក

ចាន់_សុខនី

កំណត់សំគាល់:

B1- អាគារការិយាល័យចាស់ត្រូវគ្រោងកំទេចចោល ២ ជាន់

ទំហំដីឃ្លាំងតាមបញ្ជីអចលនទ្រព្យសរុប(យោងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.ន ០០៤៤៨១) = 14,869 m²

(ឆ្នូត) - ទីតាំងដីស្នើសុំជូន លោកស៊ឹម សុត្ថា ទំហំ 7m x 20m	= 140 m²	= 1,790 m²
1 2 - ទីតាំងដីបានកាត់ចេញជូនប្រជាពលរដ្ឋ ១១គ្រួសារ ស្មើនឹង ១១ឡូតិ៍ ទំហំ [(10m x 15m) x 11 ឡូតិ៍]	= 1,650 m²	
(ទទេ) - ទំហំដីនៅសល់ 14,869m² - 1,790m²	= 13,079 m²	

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងនិងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០០៣ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២១ ស្តីពីការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីយន្តការ វិធាន និងនីតិវិធីនៃការទទួលស្គាល់ ការលើកទឹកចិត្ត ការសម្របសម្រួល និងការបណ្តុះបណ្តាលលើផ្នែកធុរកិច្ចថ្មីឌីជីថល ដើម្បីលើកកម្ពស់សហគ្រិនភាពនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សំដៅជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីឌីជីថលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

មាត្រា២ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ធុរកិច្ចថ្មីឌីជីថល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **គំរូដើម**(Prototype) សំដៅដល់គំរូដំបូងនៃផលិតផលឬសេវាមានលក្ខណៈច្នៃប្រឌិតឬនវានុវត្តន៍ ដែលជាលទ្ធផលនៃការស្រាវជ្រាវ ដើម្បីត្រៀមដាក់ឱ្យដំណើរការអាជីវកម្ម។

២- **ធុរកិច្ចថ្មីឌីជីថល**(Digital Startup) សំដៅដល់ដំណើរការនៃការគ្រប់គ្រងនិងអភិវឌ្ឍនូវគំរូដើម នៃផលិតផលឬសេវាឌីជីថលដោយបុគ្គល មានលក្ខណៈច្នៃប្រឌិតសម្រាប់ធុរកិច្ចថ្មីដែលមានឱកាស រីកចម្រើនឆាប់រហ័ស ឬស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់នៃអាជីវកម្ម។

៣- **ធុរកិច្ចថ្មីដែលមានឱកាសរីកចម្រើនឆាប់រហ័ស**(High-Growth Startup) សំដៅដល់អាជីវកម្ម ដែលអាចពង្រីកនិងបង្កើនចំណូលឆាប់រហ័សដោយប្រើបច្ចេកវិទ្យាឌីជីថល និងអាចកាត់បន្ថយ ការចំណាយលើប្រតិបត្តិការរបស់ខ្លួន។

៤- **ផលិតផលឌីជីថល**(Digital Products) សំដៅដល់ផលិតផលទាំងឡាយណាដែលមានទម្រង់ ជាឌីជីថលឬប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់ដំណើរការ រក្សាទុក វិភាគនិង/ឬបញ្ជូនទិន្នន័យ ឬព័ត៌មាន។

៥- **សេវាឌីជីថល**(Digital Services) សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់តាមរយៈ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

៦- **ស្ថាបនិកធុរកិច្ចថ្មីឌីជីថល**(Digital Startup Founder) សំដៅដល់បុគ្គលដែលទទួលបាន វិញ្ញាបនបត្រទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

៧- **ស្ថានភាពមិនច្បាស់លាស់នៃអាជីវកម្ម**(Business Uncertainty) សំដៅដល់អាជីវកម្មដែលមាន ភាពមិនច្បាស់លាស់ ហើយងាយនឹងបរាជ័យ។

៨- **ប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថល**(Digital Startup Accelerator) សំដៅដល់នីតិបុគ្គលដែល បានចុះបញ្ជីស្របច្បាប់នៅក្រសួងពាណិជ្ជកម្មក្នុងការផ្តល់សេវាគាំទ្រដល់ធុរកិច្ចថ្មីឌីជីថល។

ជំពូកទី២
ស្ថាប័នមានសមត្ថកិច្ច

មាត្រា៤ .-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរជាអក្សរកាត់ថា **ក.ប.ទ.** មានសមត្ថកិច្ចគ្រប់គ្រង សម្របសម្រួល ជំរុញធុរកិច្ចថ្មីឌីជីថល និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ដែលត្រូវបានទទួលស្គាល់ស្របតាម ការកំណត់របស់អនុក្រឹត្យនេះ។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សរសេរជាអក្សរកាត់ថា **អ.ប.គ.ព.** ជាសេនាធិការ របស់ **ក.ប.ទ.** ក្នុងការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការបញ្ចប់លើការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល រួមទាំងការតាមដានអំពីវឌ្ឍនភាពនៃការវិវត្តធុរកិច្ចថ្មីឌីជីថល ដែលត្រូវបានទទួលស្គាល់ស្របតាមការកំណត់ របស់អនុក្រឹត្យនេះ។

បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សរសេរជាអក្សរកាត់ថា **ប.ប.ឌ.** ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការផ្តល់ការលើកទឹកចិត្ត ការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេសនានាដល់ធុរកិច្ចថ្មីឌីជីថល ដែលត្រូវបានទទួលស្គាល់ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានាអាចចូលរួមធ្វើការលើកទឹកចិត្ត ការសម្របសម្រួល និងការបណ្តុះបណ្តាល លើផ្នែកធុរកិច្ចថ្មីឌីជីថល ដើម្បីចូលរួមចំណែកជំរុញសហគ្រិនភាពនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍

បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សំដៅជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីឌីជីថល រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

មាត្រា៥ .-

អ.ប.គ.ឌ. ត្រូវបង្កើតនិងរក្សាបញ្ជីនៃការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ដោយកត់ត្រានូវព័ត៌មានជាក់លាក់មួយចំនួន មានជាអាទិ៍ អត្តសញ្ញាណនៃអ្នកស្នើសុំទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ព័ត៌មាននៃធុរកិច្ចថ្មីឌីជីថល កាលបរិច្ឆេទនៃការទទួលស្គាល់ ព័ត៌មាននៃការបំពេញធុរកិច្ចថ្មីឌីជីថល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

មាត្រា៦ .-

គ.ប.ឆ. ត្រូវជ្រើសរើសប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថលឱ្យធ្វើជាតំណាងនិង/ឬជួយសម្រួលដល់ធុរកិច្ចថ្មីឌីជីថលដែលបានទទួលស្គាល់ដោយ **គ.ប.ឆ.** ក្នុងការងារហិរញ្ញវត្ថុ ពន្ធដារ កម្មសិទ្ធិបញ្ញា ជាអាទិ៍ តាមការចាំបាច់ក្នុងការប្រកបអាជីវកម្មស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការជ្រើសរើសប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **គ.ប.ឆ.**។

ជំពូកទី៣
ការផ្តល់និងការបញ្ចប់ការទទួលស្គាល់ និងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល

មាត្រា៧ .-

បុគ្គលដែលមានបំណងស្នើសុំការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ត្រូវដាក់ពាក្យស្នើសុំមក **អ.ប.គ.ឌ.** ដោយមិនមានបង់កម្រៃសេវា។

លក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិតក្នុងការផ្តល់និងការបញ្ចប់ការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **គ.ប.ឆ.**។

មាត្រា៨ .-

បុគ្គលដែលបានស្នើសុំទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ដូចមានចែងក្នុងអនុក្រឹត្យនេះ និងទទួលបានវិញ្ញាបនបត្រទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ហៅថា **ស្ថាបនិកធុរកិច្ចថ្មីឌីជីថល**។

ការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ដូចមានចែងក្នុងអនុក្រឹត្យនេះ មានសុពលភាពរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រទទួលស្គាល់ពី **អ.ប.គ.ឌ.**។

មាត្រា៩ .-

ការលើកទឹកចិត្ត ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសនានាដល់ធុរកិច្ចថ្មីឌីជីថល ដែលត្រូវផ្តល់ដោយ **ប.ប.ឌ** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **គ.ប.ឆ.**។

មាត្រា១០ .-

ការទទួលស្គាល់ឋានៈជាធុរកិច្ចថ្មីឌីជីថលត្រូវបញ្ចប់ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការស្នើសុំរបស់ស្ថាបនិកធុរកិច្ចថ្មីឌីជីថល។

ខ- ការផុតសុពលភាពនៃការទទួលស្គាល់ ដូចមានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

គ- តាមការសម្រេចរបស់រដ្ឋមន្ត្រី **គ.ប.ឆ.** លើមូលហេតុផ្សេងទៀត ដែលកំណត់ដោយប្រកាសដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះ។

បន្ទាប់ពីបញ្ចប់ការទទួលស្គាល់ឋានៈជាធុរកិច្ចថ្មីឌីជីថលហើយ បុគ្គលមានសក្តានុពលអាជីវកម្មត្រូវបានលើកទឹកចិត្តឱ្យចុះបញ្ជីពាណិជ្ជកម្មនិងបំពេញកាតព្វកិច្ចនានាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដើម្បីបន្តដំណើរការនិងពង្រីកអាជីវកម្មតទៅមុខទៀត។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា១១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ជា វ៉ាន់ដេត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១០៣ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាង ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការត្រួតពិនិត្យការបំពុលទឹក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការត្រួតពិនិត្យការបំពុលទឹក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រាមួយ .-

មាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និង ឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានធ្វើការកែសម្រួល ដូចតទៅ៖

មាត្រា៤ ._ ថ្មី

ការបញ្ចេញសំណល់រាវពីប្រភពបំពុលនានា ត្រូវអនុលោមតាមកម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវដែលមានចែងក្នុងតារាងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

មាត្រា៩ ._ ថ្មី

ហាមឃាត់ជាដាច់ខាតៈ

ក-ការបញ្ចេញទឹកកខ្វក់ពីប្រភពបំពុលចូលទៅក្នុងបណ្តាញលូសាធារណៈឬតំបន់ទឹកសាធារណៈ ដោយមិនបានធ្វើប្រព្រឹត្តកម្មសម្អាតឬមិនឆ្លើយតបស្តង់ដាបញ្ចេញដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ-ការបញ្ចេញសំណល់រាវមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

គ-ការបង្កប់លូឬការបូមបញ្ចេញសំណល់រាវវាងមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

ឃ-ការមិនដាក់ឱ្យដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវឬដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

មាត្រា១១ ._ ថ្មី

ប្រភពបំពុលដែលតម្រូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ មានបីកម្រិតដូចខាងក្រោមៈ

ក-ប្រភពបំពុលកម្រិតទី១ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង៤០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

ខ-ប្រភពបំពុលកម្រិតទី២ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង២០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

គ-ប្រភពបំពុលកម្រិតទី៣ តម្រូវឱ្យមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ទោះបីក្នុងបរិមាណណាក៏ដោយ។

នីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

មាត្រា១២ ._ ថ្មី

ការស្នើសុំបញ្ចេញចោលនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែៈ

ក-មានការបំពាក់បរិក្ខារប្រព្រឹត្តកម្មសម្អាតសំណល់រាវ និងបញ្ចេញសំណល់រាវបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្ថិតក្នុងស្ថានភាពដំណើរការជាប្រក្រតី។

ខ- ការបញ្ចេញសំណល់រាវ គឺបានឆ្លើយតបនឹងស្តង់ដានៃការបញ្ចេញសំណល់រាវ។

ការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែៈ

ក-មានការបញ្ជាក់ច្បាស់ពីគោលបំណងនៃការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវ និងមធ្យោបាយគ្រប់គ្រងសំណល់របស់ទីតាំងដែលទទួលសំណល់រាវ។

ខ-បានបំពេញលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

មាត្រា១៧.- ថ្មី

លិខិតអនុញ្ញាតបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ ត្រូវព្យួរជាបណ្ដោះអាសន្នឬដកហូតជាស្ថាពរ ក្នុងករណីណាមួយដូចខាងក្រោម៖

ក-មិនបានអនុវត្តត្រឹមត្រូវតាមស្តង់ដានៃការបញ្ចេញសំណល់រាវ។

ខ-ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវ ដែលមានកំណត់ក្នុងលិខិតអនុញ្ញាត។

គ-កើតមានករណីការបំពុលបរិស្ថានឬការបង្កគ្រោះថ្នាក់ដល់សុខភាពបណ្តាលមកពីសកម្មភាពគ្រប់គ្រងសំណល់រាវមានការខ្វះចន្លោះឬការធ្វេសប្រហែស។

មាត្រាពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥ ១៣ ខែបឋមាសាឍឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ២
កម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវ

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	បរិមាណសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញចូល		
			តំបន់ទឹកសាធារណៈប្រភេទទី១	តំបន់ទឹកសាធារណៈប្រភេទទី២	បណ្តាញលូភ្ជាប់ទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម
១	សីតុណ្ហភាព⁹ (T)	°C	<៤០	<៤០	<៤៥
២	ពណ៌ (Color)	mg Pt/l	<៥០	<១៥០	<៣០០
៣	សារធាតុរឹងអណ្តែតក្នុងទឹក (TSS)	mg/l	<៥០	<១០០	<២០០
៤	pH		៦-៩	៥,៥-៩	៥-៩
៥	BOD_5	mg/l	<៣០	<៦០	<២០០
៦	COD ($Cr_2O_7^{-2}$)	mg/l	<៦០	<១២០	<៣០០
៧	ប្រេងឬខ្លាញ់ (Oil & grease)	mg/l	<៥	<១០	<៣០
៨	សាប៊ូ (Detergent)	mg/l	<៥	<១០	<៣០
៩	អាម៉ូញាក់ (NH_3- as N)	mg/l	<៧	<១០	<៣០
១០	នីត្រាត (NO_3^{-1} as N)	mg/l	<១០	<២០	-
១១	ក្លរក្នុងទំរង់សេរី (Cl_2)	mg/l	<១	<២	-
១២	ក្លរជាអ៊ីយ៉ុង (Cl^-)	mg/l	<៥០០	<១០០០	-
១៣	ផូស្វាត (PO_4^{-3})	mg/l	<២	<៥	-
១៤	អាសូតសរុប (T-N)	mg/l	<២០	<៤០	-
១៥	ផូស្វ័រ (T-P)	mg/l	<៤	<៦	-
១៦	អ៊ីដ្រូសែនស៊ុលហ្វីត (H_2S)	mg/l	<០,២	<០,៥	<១
១៧	ម៉ង់កាណែស (Mn)	mg/l	<១	<៣	<៥
១៨	បរ (B)	mg/l	<១	<២,៥	<៥
១៩	បារ្យ៉ូម (Ba)	mg/l	<២	<៥	<៧
២០	ស្យានីតក្នុងទំរង់សេរី (CN^{-1})	mg/l	<០,១	<០,២	<១
២១	ស្យានីតសរុប (CN)	mg/l	<១	<១,៥	<២
២២	អាសេនិច (As)	mg/l	<០,០៥	<០,១	<០,៥
២៣	ដែក (Fe)	mg/l	<១	<៥	<២០
២៤	សំណ (Pb)	mg/l	<០,១	<០,៣	<០,៥
២៥	ស័ង្កសី (Zn)	mg/l	<២	<៥	<១០
២៦	ទង់ដែង (Cu)	mg/l	<១	<២	<៥
២៧	ក្រូម (Cr^{+6})	mg/l	<០,០៥	<០,១	<០,៥
២៨	កាត់ម្យូម (Cd)	mg/l	<០,០៥	<០,១	<០,៥
២៩	នីកែល (Ni)	mg/l	<០,២	<០,៥	<២
៣០	សេលេញ៉ូម (Se)	mg/l	<០,០២	<០,៥	<២

៣១	បារ៉ត (Hg)	mg/l	<0,00៥	<0,0១	<0,0៥
៣២	ផេណុល (C_6H_6O)	mg/l	<0,៥	<១	<៥

កំណត់សម្គាល់៖

តំបន់ទឹកសាធារណៈប្រភេទទី១៖ សំដៅដល់ប្រភពទឹកបិទមានជាអាទិ៍ ស្រះ ត្រពាំង បឹង ទីទំនាប រួមបញ្ចូលទាំង ប្រឡាយទឹក អូរ ព្រែក ស្ទឹង ដែលមិនមានចរន្តទឹកហូរនៅរដូវប្រាំង។

តំបន់ទឹកសាធារណៈប្រភេទទី២៖ សំដៅដល់ប្រភពទឹកចំហមានជាអាទិ៍ សមុទ្រ ទន្លេ ពាម រួមបញ្ចូលទាំង ប្រឡាយទឹក ព្រែក ស្ទឹង ដែលមានចរន្តទឹកហូរនៅរដូវប្រាំង។

(-) ៖ ពុំមានកំណត់តម្លៃ

(១)៖ ករណីការបញ្ចេញសំណល់រាវឬទឹកដែលប្រើប្រាស់សម្រាប់ការបញ្ចុះកម្ដៅម៉ាស៊ីនគ្រឿងចក្រដែលមានបរិមាណលើសពី៥០០០ម៉ែត្រគូបក្នុងមួយថ្ងៃ សីតុណ្ហភាពទឹកបញ្ចេញអាចអនុញ្ញាតក្នុងកម្រិត៥℃ (អង្សាសេ)លើសសីតុណ្ហភាពប្រភពទឹកទទួលនៅចំណុចចម្ងាយ៥០០ម៉ែត្រពីប្រាំងឬចំណុចបញ្ចេញ។

តារាងឧបសម្ព័ន្ធ៣
ប្រភពបំពុលដែលតម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោលឬដឹកសំណល់រាវទៅកាន់កន្លែងដទៃ

ល.រ	ប្រភពបំពុល	កម្រិតទី	កូដ(ISIC)
១	ទីតាំងផលិតសម្លៀកបំពាក់	១	1410
២	ទីតាំងផលិតផលិតផលនិងសម្ភារៈពីរោមសត្វ		1420
៣	ទីតាំងផលិតសម្លៀកបំពាក់ដោយចាក់និងត្បាញ		1430
៤	ទីតាំងផលិតផលិតផលនិងសម្ភារៈប្រើប្រាស់ផ្សេងៗចេញពីកៅស៊ូធម្មជាតិ ឬកៅស៊ូសំយោគ(ក្រៅពីកង់រថយន្ត)	១	2219
៥	ទីតាំងផលិតផលិតផលនិងសម្ភារៈពីសេរាមិចនិងព័រស៊ឺឡែន	១	2393
៦	ទីតាំងផលិតស៊ីម៉ងត៍ កំបោរ និងម្នាងសិលា		2394
៧	ទីតាំងផលិតផលិតផលសម្រាប់សំណង់ពីបេតុង		2395
៨	ទីតាំងកាត់ថ្ម សំលៀង និងផលិតផលិតផល និងសម្ភារៈពីថ្ម		2396
៩	ទីតាំងផលិតគ្រឿងសង្ហារឹម	១	3100
១០	ទីតាំងជួសជុលឧបករណ៍អុបទិកនិងឧបករណ៍អេឡិចត្រូនិក	១	3313
១១	ទីតាំងជួសជុលយានយន្តដឹកជញ្ជូន លើកលែងម៉ូតូ		3315
១២	ទីតាំងដំឡើងម៉ាស៊ីននិងឧបករណ៍ឧស្សាហកម្ម		3320
១៣	ទីតាំងផលិតខ្សែ ខ្សែពួ និងសំណាញ់	១	1394
១៤	ទីតាំងជីករ៉ែធម្មជាតិនិងខនិជ មានជាអាទិ៍រ៉ែផូស្វាត រ៉ែប៉ូតាស្យូម រ៉ែម៉ាញ៉េស្យូម	២	0891
១៥	ទីតាំងមន្ទីរពេទ្យនិងសម្ភព	២	8610
១៦	ទីតាំងចិញ្ចឹមគោនិងក្របី	២	0141
១៧	ទីតាំងចិញ្ចឹមសេះ		0142
១៨	ទីតាំងចិញ្ចឹមចៀមនិងពពែ		0144
១៩	ទីតាំងចិញ្ចឹមជ្រូក		0145
២០	ទីតាំងចិញ្ចឹមមាន់និងទា		0146
២១	ទីតាំងសត្តឃាត	២	-
២២	ទីតាំងបង្កកនិងកែច្នៃកៅស៊ូក្រេប		-
២៣	ទីតាំងវារីវប្បកម្មទឹកប្រៃ	២	0321
២៤	ទីតាំងវារីវប្បកម្មទឹកសាប		0322
២៥	ទីតាំងកែច្នៃនិងថែរក្សាសាច់	២	1010
២៦	ទីតាំងកែច្នៃនិងថែរក្សាផលិតផលជលផល		1020
២៧	ទីតាំងកែច្នៃនិងថែរក្សាបន្លែនិងផ្លែឈើគ្រប់ប្រភេទ		1030
២៨	ទីតាំងផលិតប្រេងពីរុក្ខជាតិនិងខ្លាញ់សត្វ		1040

២៩	ទីតាំងផលិតទឹកដោះនិងផលិតផលពីទឹកដោះ		1050
៣០	ទីតាំងផលិតផលិតផលពីធញ្ញជាតិ		1061
៣១	ទីតាំងផលិតម្សៅមីនិងផលិតផលពីម្សៅមី		1062
៣២	ទីតាំងផលិតស្ករ		1072
៣៣	ទីតាំងផលិតកាកាវនិងសូកូឡា		1073
៣៤	ទីតាំងផលិតមីនិងគុយទាវ		1074
៣៥	ទីតាំងផលិតផលិតផលអាហារ		1079
៣៦	ទីតាំងផលិតចំណីសត្វ		1080
៣៧	ទីតាំងផលិតស្រាឬអាល់កុល (កម្រិតអាល់កុលខ្ពស់)	២	1101
៣៨	ទីតាំងផលិតស្រាឬភេសជ្ជៈ (កម្រិតអាល់កុលទាប)		1102
៣៩	ទីតាំងផលិតស្រាបៀរ		1103
៤០	ទីតាំងផលិតភេសជ្ជៈនិងទឹកបរិសុទ្ធ		1104
៤១	ទីតាំងផលិតសរសៃអំបោះ អំបោះហុង អំបោះឡែន	២	1311
៤២	ទីតាំងតម្បាញក្រណាត់ ក្រណាត់សូត្រ ស្បៃ		1312
៤៣	ទីតាំងផលិតក្រណាត់ដោយចាក់និងប៉ាក់		1391
៤៤	ទីតាំងផលិតកួយ ក្រណាត់តង់ ក្រណាត់កម្រាល វាំងនន		1392
៤៥	ទីតាំងផលិតកម្រាលព្រំ		1393
៤៦	ទីតាំងផលិតក្តារបន្ទះ ឈើសន្លឹក ឈើកំណាល់រថភ្លើង	២	1621
៤៧	ទីតាំងផលិតគ្រឿងបង្គុំសំណង់ពីឈើ		1622
៤៨	ទីតាំងផលិតម្សៅក្រដាស ក្រដាស និងផលិតផលពីក្រដាស	២	1701
៤៩	ទីតាំងផលិតគ្រឿងអលង្ការកាឡៃនិងខ្សែនាឡិកាពីលោហៈ	២	3212
៥០	ទីតាំងផលិតឧបករណ៍ភ្លេង		3220
៥១	ទីតាំងផលិតសម្ភារៈកីឡា		3230
៥២	ទីតាំងផលិតសម្ភារៈល្បែងនិងតុក្កតា		3240
៥៣	ទីតាំងផលិតឧបករណ៍វេជ្ជសាស្ត្រ		3250
៥៤	ទីតាំងជីករ៉ែ (បាសាល់ ក្រាហ្វីត ត្បូង ក្វាត និងរ៉ែស៊ីលីកាត)	៣	0899
៥៥	ទីតាំងបូមយកប្រេងឆៅ	៣	0610
៥៦	ទីតាំងដកយកឧស្ម័នធម្មជាតិ		0620
៥៧	ទីតាំងវាយនភ័ណ្ឌសម្រេច មានដកពណ៌ឬជ្រលក់ពណ៌	៣	1313
៥៨	ទីតាំងផលិត ចម្រាញ់ប្រេងកាត	៣	1920
៥៩	ទីតាំងផលិតសារធាតុគីមី	៣	2011
៦០	ទីតាំងផលិតជីនិងសមាសធាតុអាស៊ូត		2012
៦១	ទីតាំងផលិតប្លាស្ទិកនិងកៅស៊ូសំយោគ (ទំរង់បឋម)		2013
៦២	ទីតាំងផលិតថ្នាំសម្លាប់សត្វល្អិតនិងផលិតផលគីមីកសិកម្ម		2021
៦៣	ទីតាំងផលិតថ្នាំពណ៌ ថ្នាំលាប ថ្នាំប៉ូលា ថ្នាំបោះពុម្ព និងជីលែង		2022

៦៤	ទីតាំងផលិតសាប៊ូដុំ សាប៊ូម្សៅ និងសាប៊ូទឹក		2023
៦៥	ទីតាំងផលិតឱសថពីគីមីនិងពីរុក្ខជាតិ	៣	2100
៦៦	ទីតាំងផលិតសំបកកង់ បំពង់ជ័រពីកៅស៊ូ និងកែច្នៃឡើងវិញ	៣	2211
៦៧	ទីតាំងផលិតផលិតផលនិងសម្ភារៈពីប្លាស្ទិក		2220
៦៨	ទីតាំងផលិតដែកនិងដែកថែប	៣	2410
៦៩	ទីតាំងផលិតលោហធាតុមានតម្លៃនិងលោហធាតុមិនមែនដែក		2420
៧០	ទីតាំងផលិតផលិតផលពីលោហៈ		2431
៧១	ទីតាំងស្លរំលាយលោហៈមិនមែនដែក		2432
៧២	ទីតាំងផលិតផលិតផលសំណង់ពីលោហធាតុ	៣	2511
៧៣	ទីតាំងផលិតធុង អាង និងប្រអប់ដែលធ្វើពីលោហធាតុ		2512
៧៤	ទីតាំងផលិតម៉ាស៊ីនចំហាយឬគ្រឿងបង្គុំ		2513
៧៥	ទីតាំងដំ សង្កត់ និងរមូរដែកឬលោហធាតុ		2591
៧៦	ទីតាំងស្លរំលាយ ចាក់ពុម្ព និងស្រោបលោហធាតុ		2592
៧៧	ទីតាំងផលិតគ្រឿងបន្លាស់អេឡិចត្រូនិក	៣	2610
៧៨	ទីតាំងផលិតកុំព្យូទ័រនិងគ្រឿងបង្គុំ		2620
៧៩	ទីតាំងផលិតឧបករណ៍ទំនាក់ទំនង		2630
៨០	ទីតាំងផលិតគ្រឿងអេឡិចត្រូនិក		2640
៨១	ទីតាំងផលិតឧបករណ៍វាស់ តេស្ត រុករក និងត្រួតពិនិត្យ		2651
៨២	ទីតាំងផលិតនាឡិកាដៃនិងនាឡិកាប៉ោល		2652
៨៣	ទីតាំងផលិតឧបករណ៍អុបទិក		2670
៨៤	ទីតាំងផលិតឧបករណ៍ប្រព័ន្ធផ្សព្វផ្សាយអុបទិកនិងម៉ាញ៉េទិក		2680
៨៥	ទីតាំងផលិតម៉ាស៊ីនភ្លើង ម៉ូទ័រ ឧបករណ៍បញ្ជានិងចែកចាយចរន្តអគ្គិសនី	៣	2710
៨៦	ទីតាំងផលិតថ្មពិល អាគុយ		2720
៨៧	ទីតាំងផលិតខ្សែកាបអុបទិក		2731
៨៨	ទីតាំងផលិតខ្សែភ្លើងនិងខ្សែកាបអគ្គិសនី		2732
៨៩	ទីតាំងផលិតឧបករណ៍ខ្សែភ្លើង		2733
៩០	ទីតាំងផលិតអំពូលភ្លើងគ្រប់ប្រភេទ		2740
៩១	ទីតាំងផលិតប្រេងម៉ាស៊ីន	៣	2811
៩២	ទីតាំងផលិតម៉ាស៊ីនបូម ម៉ាស៊ីនបង្កើនសម្ពាធខ្យល់ ស្នប់		2813
៩៣	ទីតាំងផលិតចង្កូត ស្ពឺ ប្រអប់លេខ និងគ្រឿងបង្គុំ		2814
៩៤	ទីតាំងផលិតឧបករណ៍សម្រាប់លើកដាក់		2816
៩៥	ទីតាំងផលិតគ្រឿងបរិក្ខារនិងសម្ភារៈការិយាល័យ		2817
៩៦	ទីតាំងផលិតគ្រឿងយន្តកសិកម្ម		2821
៩៧	ទីតាំងផលិតគ្រឿងយន្តសម្រាប់ការរុករករ៉ែនិងសំណង់		2824
៩៨	ទីតាំងផលិតគ្រឿងយន្តសម្រាប់កែច្នៃម្ហូបអាហារ ភេសជ្ជៈនិងថ្នាំជក់		2825

៩៩	ទីតាំងផលិតគ្រឿងយន្តសម្រាប់វាយនភ័ណ្ឌ		2826
១០០	ទីតាំងផលិតយានយន្ត	៣	2910
១០១	ទីតាំងផលិតតួទោចក្រយានយន្ត យានយន្ត និងកន្ទុយសណ្តោង		2920
១០២	ទីតាំងផលិតគ្រឿងបន្លាស់និងគ្រឿងបង្គុំយានយន្ត		2930
១០៣	ទីតាំងសាងសង់នាវានិងសំណង់បណ្តែតទឹក	៣	3011
១០៤	ទីតាំងសាងសង់ទូកកម្សាន្តនិងកីឡា		3012
១០៥	ទីតាំងផលិតទោចក្រយានយន្ត		3091
១០៦	ទីតាំងផលិតកង់		3092
១០៧	ទីតាំងប្រព្រឹត្តកម្មសំណល់រាវ (តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម)	៣	3700
១០៨	ទីតាំងប្រព្រឹត្តកម្មនិងបោះចោលសំណល់មិនមែនគ្រោះថ្នាក់	៣	3821
១០៩	ទីតាំងប្រព្រឹត្តកម្មនិងបោះចោលសំណល់គ្រោះថ្នាក់		3822
១១០	ទីតាំងសម្លាប់ស្បែកឬកែច្នៃរោមសត្វ	៣	-
១១១	ទីតាំងអាជីវកម្មរ៉ែមាស		-
១១២	ទីតាំងផលិតអគ្គិសនី		-
១១៣	ទីតាំងស្រាវជ្រាវ និងអភិវឌ្ឍការពិសោធន៍លើវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម	៣	7210

កំណត់សម្គាល់៖

(ISIC) ៖ ចំណាត់ថ្នាក់ឧស្សាហកម្មស្តង់ដាអន្តរជាតិ (International Standard Industry Classification)

(-) ៖ ពុំមានលេខកូដ

តារាងឧបសម្ព័ន្ធ៤

កម្រិតកំណត់ស្តង់ដាគុណភាពទឹកតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវៈចម្រុះនៅក្នុងទឹក

លរ	ប៉ារ៉ាម៉ែត្រ	ខ្នាត	កម្រិតកំណត់ស្តង់ដា		
			តំបន់ទឹកសាធារណៈប្រភេទទី១	តំបន់ទឹកសាធារណៈប្រភេទទី២	ទឹកសមុទ្រ
១	pH		៦,៥-៨,៥	៦,៥-៨,៥	៧,០-៨,៣
២	កម្រិតរលាយអុកស៊ីសែន(DO)	mg/l	>៣	>៤	>៤
៣	BOD_5	mg/l	<៨	<៦	-
៤	COD_{Mn}	mg/l	<១០	<៨	<៨[១]
៥	សារធាតុរឹងអណ្តែតក្នុងទឹក(TSS)	mg/l	<១០០	<១០០	<៨០
៦	ជាតិអំបិល (Salinity)	mg/l	<១០០០	<១០០០	-
៧	នីត្រាត (NO_3^{-1} as N)	mg/l	<២,៤	<១,២	<០,០៦
៨	អាសូតសរុប (T-N)	mg/l	<៣	<២	<២
៩	ផូស្វ័រសរុប (T-P)	mg/l	<០,២៥	<០,១៥	<០,០៩
១០	ប្រេង ឬខ្លាញ់(Oil & grease)	mg/l	-	-	<០,១៤

កំណត់សម្គាល់៖

តំបន់ទឹកសាធារណៈប្រភេទទី១៖ សំដៅដល់ប្រភពទឹកបិទមានជាអាទិ៍ បឹង ត្រពាំង ស្រះ ទីទំនាប រួមបញ្ចូលទាំងស្ទឹង ព្រែក អូរ និងប្រឡាយទឹកដែលមិនមានចរន្តទឹកហូរនៅរដូវប្រាំង។

តំបន់ទឹកសាធារណៈប្រភេទទី២៖ សំដៅដល់ប្រភពទឹកចំហមានជាអាទិ៍ ទន្លេ ពាម រួមបញ្ចូលទាំងស្ទឹង ព្រែក អូរ និងប្រឡាយទឹកដែលមានចរន្តទឹកហូរនៅរដូវប្រាំង។

(-) ៖ ពុំមានកំណត់តម្លៃ

[១]៖ សំដៅដល់តម្រូវការអុកស៊ីសែនតាមបែបប៉ូតាស្យូមពែម៉ង់កាណាតអាល់កាឡាំង $COD_{(OH)}$

តារាងឧបសម្ព័ន្ធ៥

កម្រិតកំណត់ស្តង់ដាគុណភាពទឹកតំបន់ទឹកសាធារណៈ សម្រាប់ការការពារសុខភាពសាធារណៈ

លរ	ប៉ារ៉ាម៉ែត្រ	ខ្នាត	កម្រិតស្តង់ដា	កូដ (CAS No.)
១	កាបូនតេត្រាក្លរ (CCl_4)	μg/l	<៤	(56-23-5)
២	អ៊ិចសាក្លរ៉ូបង់សែន (C_6Cl_6)	μg/l	<0,0៣	(118-74-1)
៣	ដេដេតេ (DDT)	μg/l	<១	(50-29-3)
៤	អង់ទ្រីន($C_{12}H_8Cl_6O$)	μg/l	<0,0១	(72-20-8)
៥	ឌីអលទ្រីន ($C_{12}H_8Cl_6O$)	μg/l	<0,0១	(60-57-1)
៦	អេនទ្រីន ($C_{10}H_{13}NO_3$)	μg/l	<0,00៥	(309-00-2)
៧	អ៊ីសូទ្រីន ($C_{12}H_8Cl_6$)	μg/l	<0,00៥	(465-73-6)
៨	ពែក្លរ៉ូអេទីឡែន (C_2Cl_4)	μg/l	<១0	(127-18-4)
៩	អ៊ិចសាក្លរ៉ូប៊ុយតាឌីអែន (C_4Cl_6)	μg/l	<0,0១	(87-68-3)
១០	ក្លរ៉ូហ្វម ($CHCl_3$)	μg/l	<៣00	(67-66-3)
១១	១,២ ឌីក្លរ៉ូអេទីឡែន ($C_2H_2Cl_2$)	μg/l	<៤0	(156-59-2)
១២	ទ្រីក្លរ៉ូអេទីឡែន (C_2HCl_3)	μg/l	<១0	(79-01-6)
១៣	១,២,៤ ទ្រីក្លរូបង់សែន($C_6H_3Cl_3$)	μg/l	<0,៤	(120-82-1)
១៤	អ៊ិចសាក្លរ៉ូស៊ីក្លូអ៊ិចសែន($C_6H_6Cl_6$)	μg/l	<0,0៥	(58-89-9)
១៥	បង់សែន (C_6H_6)	μg/l	<១0	(71-43-2)
១៦	កាត់ម្ញូម (Cd)	μg/l	<៣	(7440-43-9)
១៧	បារ៉តសរុប (Hg)	μg/l	<0,៥	(7439-97-6)
១៨	បារ៉តសរីរាង្គ (CH_3Hg^+ និង C_6H_5Hg)	μg/l	មិនអាចរកឃើញ	-
១៩	សំណ (Pb)	μg/l	<១0	(7439-92-1)
២០	ក្រូមៀ៉ឡង់៦ (Cr^{+6})	μg/l	<៥0	(18540-29-9)
២១	អាសេនិច (As)	μg/l	<១0	(7440-38-2)
២២	សេលេញ៉ូម (Se)	μg/l	<១0	(7782-49-2)
២៣	ប៉ូលីក្លរ៉ូ ប៊ីផេនីល (PCB)	μg/l	មិនអាចរកឃើញ	(1336-36-3)
២៤	ស្យានីតសរុប (CN)	μg/l	<៥	(57-12-5)
២៥	ឌីក្លរ៉ូមេតាន (CH_2Cl_2)	μg/l	<២0	(75-09-2)
២៦	កូលីហ្វមសរុប(Total coliform)	MPN /100mL	<១000	-

កំណត់សម្គាល់៖

កូដ CAS No. ៖ សំដៅដល់លេខកូដសារធាតុគីមី (Chemical Abstract Service Number)

(-) ៖ ពុំមានកំណត់លេខកូដ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩៥.អនក្រ.តត

អនុក្រឹត្យ
ស្ដីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- ប្រគល់ភារកិច្ចជូនលោក **តា ចន្ទ្រា** ឱ្យបំពេញមុខងារជាប្រធានមណ្ឌលយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩៦ អនក្រ.តត

អនុក្រឹត្យ
ស្ដីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តែងតាំងលោក **ឡេង គឹមស្រុង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន របស់ក្រសួងបរិស្ថាន។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៩៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការប្តូរឈ្មោះ "សាកលវិទ្យាល័យមានជ័យ" មកជា "សាកលវិទ្យាល័យជាតិមានជ័យ"
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់របទានសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរបទានសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តែងតាំងមន្ត្រីរាជការចំនួន ០៣ រូប របស់សាកលវិទ្យាល័យជាតិមានជ័យ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

១-លោក **ផុន សុផិន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា ជំនួសលោក **ជីវ សារិទ្ធ** ដែលទទួលភារកិច្ចថ្មី

២-លោក **ខៅ ច័ន្ទនរៈ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ ជំនួសលោក **ទេព វុទ្ធី** ដែលបានផ្ទេរចេញ

៣-លោក **ឆី សុជាតិ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ ជំនួសលោក **គង់ វណ្ណៈ** ដែលបានផ្ទេរចេញ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការលុបឈ្មោះមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : លុបឈ្មោះលោក **ឝួច ផលគុណ** ប្រធាននាយកដ្ឋានកសិកម្មនិងធនធានទឹក នៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញពីក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ ដោយមូលហេតុទទួលមរណភាព។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៩៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអភិបាល នៃគណៈអភិបាលស្រុក ក្នុងខេត្តកំពង់ចាម សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោមៈ

១- លោក **ចិន ឡាដា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលស្រុកកំពង់សៀម

២- លោក **ស៊ឹម គន់** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលស្រុកស្រីសន្ធរ

៣- លោក **ឡោ ចាន់លី** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលស្រុកព្រៃឈរ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៧០ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.- បំពាក់មេដាយ**សហមេត្រី** តាមលំដាប់ថ្នាក់ ជូនជូននាយទាហានថៃ និងអនុព័ន្ធយោធារុស្ស៊ី ចំនួន ៥រូប ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ កន្លងមកដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **សហមេត្រី** ថ្នាក់ **សេនា**

១-ឧត្តមសេនីយ៍ឯក	TERDSAK DUMKHUM	អគ្គនាយក អគ្គនាយកដ្ឋានចារកម្ម កងទ័ពជើងគោកភូមិន្ទថៃ
២-វរនាវីឯក	Ivan STADCHENKO	នាយការិយាល័យអនុព័ន្ធយោធារុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា

ខ-មេដាយ **សហមេត្រី** ថ្នាក់ **អស្សប្ញទ្ធិ**

១-ឧត្តមសេនីយ៍ទោ	DIREK BONGKARN	អគ្គនាយករង អគ្គនាយកដ្ឋានចារកម្ម កងទ័ពជើងគោកភូមិន្ទថៃ
២-ឧត្តមសេនីយ៍ទោ	KAMCHAI WONGSRI	នាយក នាយកដ្ឋានសហប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋាន ចារកម្ម កងទ័ពជើងគោកភូមិន្ទថៃ

៣-វរសេនីយ៍ឯកពិសេស MAYTEE PROMPRIANGCHAI ប្រធានការិយាល័យសម្របសម្រួលប្រទេសជិតខាង

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.- បំពាក់មេដាយ**សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហាន ចំនួន ៤រូប នៃកងទ័ពជើងគោកភូមិន្ទថៃ ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម៖

១-នាយឧត្តមសេនីយ៍ APIRAT KONGSOMPONG អតីតមេបញ្ជាការ កងទ័ពជើងគោកភូមិន្ទថៃ

២-នាយឧត្តមសេនីយ៍ NARONGPAN JITTKAEWTAE មេបញ្ជាការ កងទ័ពជើងគោកថៃ

៣-នាយឧត្តមសេនីយ៍ TEERAWAT BOONYAWAT នាយសេនាធិការ កងទ័ពជើងគោកភូមិន្ទថៃ

៤-នាយឧត្តមសេនីយ៍ WARAKIAT RATTANANONT នាយសេនាធិការ រងកងទ័ពជើងគោកភូមិន្ទថៃ

មាត្រា២.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះកម្ពុជាសម្រាប់ជំរុញការអនុវត្ត អនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃ ស្តីពីតំបន់ទាមទារដែនសមុទ្រត្រួតគ្នានៃតំបន់ខ្ពង់រាបបាតសមុទ្រឆ្នាំ២០០១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១ .-

ត្រូវបានបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះកម្ពុជាសម្រាប់ជំរុញការអនុវត្តអនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃស្តីពីតំបន់ទាមទារដែនសមុទ្រត្រួតគ្នានៃតំបន់ខ្ពង់រាបបាតសមុទ្រឆ្នាំ២០០១ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម **ទា គីមហុង**	ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន	អនុប្រធាន
៣- ឯកឧត្តម **ស៊ុយ សែម**	រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល	អនុប្រធានប្រចាំការ
៤- ឯកឧត្តម **ស៊ា កុសល**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៥- ឯកឧត្តម **វង្សី វិស្សុត**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៦- ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ		សមាជិក
៧- លោកជំទាវ **គុយ ពិសី**	អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន	សមាជិក
៨- ឯកឧត្តម **ស៊ា ម៉ៅ**	អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៩- ឯកឧត្តម **លី ច័ន្ទតុលា**	អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
១០- ឯកឧត្តម **ឈៅ ធួក**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១១-ឯកឧត្តម **ហូ វិចិត្រ**	រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល	សមាជិក
១២-ឯកឧត្តម **ម៉េង សក្តិធារ៉ា**	រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល	សមាជិក
១៣-ឯកឧត្តម **សុខ ខាវ៉ាន់**	រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល	សមាជិក
១៤- ឯកឧត្តម **អ៊ាង សុផល្លែត**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១៥- ឯកឧត្តម **ឆៀ វិញ**	មេបញ្ជាការកងទ័ពជើងទឹកនិងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ	សមាជិក
១៦- ឯកឧត្តម **ជៀប សួរ**	អគ្គនាយកប្រេងកាតនៃក្រសួងរ៉ែនិងថាមពល	សមាជិក
១៧-លោកបណ្ឌិត **គីក ម៉េង**	ប្រធាននាយកដ្ឋានសិក្សាអាម៉េរិក អាម៉េរិកឡាទីន និងអូសេអានីនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា	សមាជិក។

ប្រការ២ ._

គណៈកម្មាធិការបច្ចេកទេសចម្រុះកម្ពុជាសម្រាប់ជំរុញការអនុវត្តអនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃស្តីពីតំបន់ទាមទារដែនសមុទ្រត្រួតគ្នានៃតំបន់ខ្ពង់រាបបាតសមុទ្រឆ្នាំ២០០១ មានភារកិច្ចដូចតទៅ៖

- ចរចានិងស្វែងរកការឯកភាពគ្នារវាងភាគីទាំងពីរលើបញ្ញត្តិនានាសម្រាប់ការតាក់តែងសន្ធិសញ្ញាស្តីពីការអភិវឌ្ឍរួមគ្នា ដោយរួមបញ្ចូលទាំងការបង្កើតមូលដ្ឋានដែលអាចទទួលយកបានដោយភាគីទាំងពីរ សម្រាប់ការបែងចែកបន្ទុកចំណាយនិងផលពីការធ្វើអាជីវកម្មធនធានប្រេងកាតនៅក្នុងតំបន់អភិវឌ្ឍន៍រួមគ្នាដូចមានចែងក្នុងអនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃស្តីពី

